**សកម្មភាព** ៖ ច្រៀងបទចម្រៀងតាមពណ៌ទាំងប្រាំពីរជាភាសាអង់គ្លេស

**សិក្សាសង្គម**

ចម្រៀង និងតន្ត្រី(ចំណេះដឹងបច្ចេកទេស ការច្នៃប្រឌិត និងបទពិសោធន៍តន្ត្រី)

**បុរេគណិត**

ទំហំ និងពណ៌ (ចំណាត់ក្រុម និងលំដាប់លំដោយ) ។

**គោលបំណង** ៖

**(សិក្សាសង្គម)** ច្រៀងចំរៀង និងធ្វើកាយវិការតាមបទចម្រៀងបាន។

**(បុរេគណិត)** ប្រាប់បានពីការរៀបវត្ថុតាមលំដាប់ក្រុម ទំហំ និងពណ៌។

**កម្រិតសិក្សា** ៖ ទាប មធ្យម ខ្ពស់

**សៀវភៅ** ៖ ដកស្រង់ចេញពីរឿង "តើនរណាជាអ្នកលាបពណ៌មេឃ?"

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ កាត និងវត្ថុដែលមានពណ៌ដូចនៅក្នុងបទចម្រៀង និងរូបភាពរបស់ឥន្ទធនូ។

**ការរៀបចំ** ៖ អនុវត្ត និងរៀនច្រៀងបទចម្រៀងឱ្យចេះច្បាស់ជាមុនសិន ។

**សេចក្តីណែនាំ** ៖

1. ថ្ងៃនេះអ្នកគ្រូនឹងបង្រៀនកូនៗច្រៀងបទចម្រៀងតាមពណ៌ទាំងប្រាំពីរជាភាសាអង់គ្លេសទាំងអស់គ្នា។
2. ច្រៀងបទចម្រៀងឱ្យក្មេងៗស្តាប់។
3. ក្រោយពេលច្រៀងចប់
   តើមានកូនណាដឹងថាបទចម្រៀងនេះជាភាសាអ្វី? ចាស/បាទ ភាសាអង់គ្លេស
4. អញ្ជឹងចុះយ៉េក និងខេទីនិយាយភាសាអង់គ្លេស៖ តើពួកគាត់មកពីប្រទេសណាដែរ?
   ចាស/បាទ អូស្ត្រាលី។
5. បង្ហាញពីកាតរូបភាពដែលមានពណ៌ផ្សេងៗពីគ្នាចំនួនប្រាំពីរ។
6. ឱ្យក្មេងៗថាតាមពណ៌ទាំងប្រាំពីរជាភាសាអង់គ្លេសតាមល,ដាប់លំដោយនៃបទចម្រៀង។
7. បង្ហាញរូបឥន្ទធនូ ហើយសួក្មេងៗថា៖ តើកូនៗដឹងថារូបនេះជាអ្វី? តើភាសាអង់គ្លេសគេហោះថាអ្វី?
   ក្មេងឆ្លើយថា ៖ រូបឥន្ទធនូ
   អង់គ្លេសគេហៅថា ៖**(rainbow)**ឱ្យក្មេងថាតាមឱ្យបានច្រើនដង។
8. ឱ្យក្មេងៗច្រៀងបទចម្រៀងនៅឃ្លាទី១ បណ្តើរចង្អុលពណ៌នៅលើរូបឥន្ទធនូបណ្តើរ។
9. អនុវត្តបទចម្រៀងឱ្យបានច្រើនដង បន្ទាប់មក ច្រៀងបទចម្រៀងពីដើមរហូតដល់ចប់តែម្តង។
10. ថាតាមឈ្មោះនៃពណ៌ទាំងប្រាំពីរម្តងទៀត និងឱ្យក្មេងៗទាំងអស់ថាតាមអ្នកជាកាស្រេច។

**ការប្រែប្រួល៖** លោកអ្នកអាចជ្រើសរើសបទចំរៀងជាភាសាខ្មែរតែរៀបរាប់អំពីពណ៌ក៏បាន។

[បទចម្រៀង ខ្ញុំអាចច្រៀងបទឥន្ទធនូបាន_I-Can-Sing-A-Rainbow]

**Red and yellow and pink and green**

(ពណ៌ក្រហម ពណ៌លឿង ពណ៌ផ្កាឈូក បៃតង)

**Purple and orange and blue**

(ស្វាយ ទឹកក្រូច និងពណ៌ខៀវស្វាយ)

**I can sing a rainbow**

(ខ្ញុំអាចច្រៀងបទឥន្ទធនូបាន)

**Sing a rainbow**

(ច្រៀងបទឥន្ទធនូ)

**Sing a rainbow for you**

(ច្រៀងបទឥន្ទធនូ សម្រាប់អ្នក)